ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៥ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងសមាសភាពអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៦ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៤៩ សសរ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការកំណត់របៀបរបបការងារនិងការបែងចែកភារកិច្ចរបស់រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៤៦ សសរ ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៩ ស្តីពីការបង្កើតអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលដូចតទៅ៖

១- ឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទទួលបន្ទុកលើកិច្ចការនាំពាក្យរាជរដ្ឋាភិបាល ប្រធាន

២- ឯកឧត្តម **ឯក ថា** អ្នកនាំពាក្យទីស្ដីការគណៈរដ្ឋមន្ត្រី អនុប្រធានប្រចាំការ
៣- ឯកឧត្តម សន្តិបណ្ឌិត **ខៀវ សុភ័គ** អ្នកនាំពាក្យក្រសួងមហាផ្ទៃ អនុប្រធាន
៤- ឯកឧត្តម នាយឧត្តមសេនីយ៍ **ឈុំ សុជាត** អ្នកនាំពាក្យក្រសួងការពារជាតិ អនុប្រធាន
៥- ឯកឧត្តម **កេត សោផាន់** អ្នកនាំពាក្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន
៦- ឯកឧត្តម **គីម សុគតៈ** អ្នកនាំពាក្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
៧- ឯកឧត្តម **ស្រី ធុឌ្ឍី** អ្នកនាំពាក្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
៨- ឯកឧត្តម **ចាន់ ដារ៉ុង** អ្នកនាំពាក្យក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
៩- ឯកឧត្តម **ស៊ាង ថៃ** អ្នកនាំពាក្យក្រសួងពាណិជ្ជកម្ម សមាជិក
១០- ឯកឧត្តម **អ៊ុំ សុថា** អ្នកនាំពាក្យក្រសួងឧស្សាហកម្មនិងសិប្បកម្ម សមាជិក
១១- ឯកឧត្តម **ស្រី ដា** អ្នកនាំពាក្យក្រសួងផែនការ សមាជិក
១២- ឯកឧត្តម **រស់ សុខាចា** អ្នកនាំពាក្យក្រសួងអប់រំ យុវជន និងកីឡា សមាជិក
១៣- ឯកឧត្តម **តូច ចាន់នី** អ្នកនាំពាក្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
១៤- ឯកឧត្តម **សេង ឡូត** អ្នកនាំពាក្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
១៥- ឯកឧត្តម **នេត្រ ភក្ត្រា** អ្នកនាំពាក្យក្រសួងបរិស្ថាន សមាជិក
១៦- ឯកឧត្តម **ចាន់ យុត្ថា** អ្នកនាំពាក្យក្រសួងធនធានទឹកនិងឧតុនិយម សមាជិក
១៧- ឯកឧត្តម **អ៊ុក គឹមសេង** អ្នកនាំពាក្យក្រសួងព័ត៌មាន សមាជិក
១៨- ឯកឧត្តម **ជិន ម៉ាលីន** អ្នកនាំពាក្យក្រសួងយុត្តិធម៌ សមាជិក
១៩- ឯកឧត្តម **ណុប ចាន់ណារិទ្ធ** អ្នកនាំពាក្យក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សមាជិក
២០- ឯកឧត្តម **មាស ម៉ុ** អ្នកនាំពាក្យក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក
២១- លោកជំទាវ **ឱ វណ្ណឌីន** អ្នកនាំពាក្យក្រសួងសុខាភិបាល សមាជិកា
២២- ឯកឧត្តម **ប៉ាល់ ចន្ទតារា** អ្នកនាំពាក្យក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក
២៣- ឯកឧត្តម **ថៃ នរៈសត្យា** អ្នកនាំពាក្យក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក
២៤- ឯកឧត្តម **តុប សុភ័គ** អ្នកនាំពាក្យក្រសួងទេសចរណ៍ សមាជិក
២៥- ឯកឧត្តម **សេង សុមុនី** អ្នកនាំពាក្យក្រសួងធម្មការនិងសាសនា សមាជិក
២៦- លោកជំទាវ **ម៉ាន ចិន្តា** អ្នកនាំពាក្យក្រសួងកិច្ចការនារី សមាជិកា
២៧- ឯកឧត្តម **ហេង សួរ** អ្នកនាំពាក្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
២៨- ឯកឧត្តម **ឈឿន ម៉ុណ្ណារ័ត្ន** អ្នកនាំពាក្យក្រសួងមុខងារសាធារណៈ សមាជិក
២៩- ឯកឧត្តម **យស មុនីរ៉ាត់** អ្នកនាំពាក្យក្រសួងរ៉ែនិងថាមពល សមាជិក
៣០- លោក **ស៊ីន ចាន់សិរីឧត្តា** អ្នកនាំពាក្យរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក។

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៨ កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ